ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ASIAN INFRASTRUCTURE INVESTMENT BANK

# ផែនការគ្រប់គ្រងសុវត្ថិភាពបរិស្ថាននិងសង្គម នៃអនុគម្រោងស្តារជួសជុលសាងសង់ផ្លូវ នៃខ្សែផ្លូវកញ្ចប់ទី២
(ខ្សែផ្លូវថ្មទទឹង - សំពៅលូន) ស្រុកមេមត់ ខេត្តត្បូងឃ្មុំ)

## សេចក្តីសង្ខេប


រាជរដ្ឋាភិបាលកម្ពុជា ទទួលបានកម្ចីពីធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (AIIB) ដែលជាហិរញ្ញប្បទាន នៃគម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទ សម្រាប់កម្មវិធីហេដ្ឋារចនាសម្ព័ន្ធជនបទ ដើម្បីឆ្លើយតបទៅនឹងការរាលដាលជម្ងឺកូវីដ-១៩។ គម្រោងនេះអនុវត្តចាប់ពីខែកុម្ភៈឆ្នាំ២០២១ ដល់ខែមិថុនាឆ្នាំ២០២៤ ដែលមានក្រសួងអភិវឌ្ឍន៍ជនបទជាស្ថាប័នប្រតិបត្តិ ក្នុងខេត្តគោលដៅចំនួន៥ខេត្ត គឺខេត្តកំពង់ឆ្នាំង ព្រៃវែង ត្បូងឃ្មុំ ខេត្តកោះកុង និងខេត្តប៉ៃលិន។ គោលបំណងរបស់គម្រោងគឺដើម្បី ទ្រទ្រង់ដល់ជីវភាពនិងសេដ្ឋកិច្ចនៅជនបទ និងប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ពីការរាលដាលជម្ងឺកូវីដ-១៩ និងការបន្សាំនឹងស្ថានភាពបម្រែបម្រួលធាតុអាកាស។ គម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទ គឺតម្រូវអោយរៀបចំផែនការគ្រប់គ្រងសុវត្ថិភាពបរិស្ថាន និងសង្គម។ លើសពីនេះ អ្នកទទួលការ ក៏ត្រូវរៀបចំផែនការសុវត្ថិភាពបរិស្ថាននិងសង្គម រួមបញ្ចូលទាំងផែនការសុខភាពនិងសុវត្ថិភាពការងារនិងយេនឌ័រ សម្រាប់អនុគម្រោងសាងសង់ផ្លូវជនបទ នៅតាមខេត្តគោលដៅ។

អនុគម្រោងខ្សែផ្លូវកញ្ចប់ទី២ (Lot 4: ខ្សែផ្លូវថ្មទទឹង - សំពៅលូន) ដែលស្ថិតនៅក្នុងឃុំជាំតាម៉ៅ និងឃុំមេមង ក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ មានប្រវែង១១,៦៨៤ម៉ែត្រ និងទទឹងប្រវែង៨ម៉ែត្រ បាននឹងកំពុងស្តារជួសជុលសាងសង់ឡើងវិញ ជាផ្លូវក្រាលកៅស៊ូពីជាន់និងបេតុងសរសៃដែក ។ ហេដ្ឋារចនាសម្ព័ន្ធផ្លូវរួមមានដូចជា សំណង់លូប្រអប់ចំនួន៧កន្លែង ក្នុងនោះសំណង់លូប្រអប់ភ្លោះកាត់ផ្លូវចំនួន១កន្លែង និងលូប្រអប់៦កន្លែងត្រូវបានរក្សាទុក។ ចំណែកសំណង់លូមូលចំនួន១៤កន្លែងក៏ត្រូវបានរក្សាទុក។ សំណង់លូមូលចំនួន៥កន្លែងផ្សេងទៀតជាសំណង់ថ្មី។ ស្ពានចំនួន១កន្លែង ក៏បានរក្សាទុកដដែល។ លើសពីនេះ សំណង់ក្រាលបេតុងប្រវែង៥០ម៉ែត្រ គឺត្រូវសាងសង់។ អនុគម្រោងនេះចាប់ផ្តើមដំណើរការសាងសង់ពីខែមិថុនា ឆ្នាំ២០២៣ រហូតដល់ខែឧសភា ឆ្នាំ២០២៤ ដោយក្រុមហ៊ុន បន្ទាយស្រី អ៊ិនជីនារីង & ខនស្រ្តាក់សិន (Banteay Srei Engineering & Construction Co., Ltd) ជាអ្នកទទួលការសាងសង់ ដែលត្រូវចំណាយថវិកាអស់ ១,៦៤១,៥០០.០០ដុល្លាអាមេរិក។

ការសិក្សាវាយតម្លៃហេតុប៉ះពាល់នៃផែនការសុវត្ថិភាពបរិស្ថាននិងសង្គម គឺបានសិក្សានៅមុនពេលដំណើរការសាងសង់។ លទ្ធផលនៃការសិក្សាវាយតម្លៃបានបង្ហាញថា ពុំមានប្រជាពលរដ្ឋដែលស្ថិតនៅសងខាងផ្លូវ ទទួលរងផលប៉ះពាល់នៃការស្តារជួសជុលសាងសង់ផ្លូវនេះឡើយ។ ផលប៉ះពាល់បរិស្ថានដែលស្ថិតនៅសងខាងផ្លូវ រួមមានដើមឈើមួយចំនួន ដែលជាសម្បត្តិសាធារណៈដែលជាចំណីផ្លូវ។ ទន្ទឹមនឹងនេះដែរ រដ្ឋបាលស្រុកមេមត់ បានបញ្ជាក់ជាលាយល័ក្ខអក្សរពីការធានាអះអាងមិនប៉ះពាល់ដល់ដីធ្លីរបស់ប្រជាពលរដ្ឋ។ ការពិភាក្សាជាសាធារណៈចំនួន២លើកបានរៀបចំឡើង ក្នុងនោះការពិភាក្សាលើកទី១បានធ្វើនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ ដែលមានប្រជាពលរដ្ឋចូលរួមចំនួន ៦១នាក់ (ស្ត្រី៧នាក់) និងការពិភាក្សាជាសាធារណៈលើកទី២ នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ មានប្រជាពលរដ្ឋចូលរួមចំនួន ៨៤នាក់ ក្នុងនោះមានស្ត្រី៣៥នាក់។

ចំពោះយន្តការបណ្តឹងតវ៉ា ឬការផ្តល់ពត៌មានពីការត្អូញត្អែរផ្សេងៗ នៅក្នុងកំលុងពេលកំពុងសាងសង់គឺប្រជា-ពលរដ្ឋអាចផ្តល់ពត៌មានដែលពាក់ព័ន្ធនឹងការសាងសង់ផ្លូវ ដើម្បីបញ្ចៀសនូវការប៉ះពាល់ជាយថាហេតុណាមួយ។ យន្តការបណ្តឹងតវ៉ា ឬការផ្តល់ពត៌មានពីការត្អូញត្អែរ គឺអាចធ្វើឡើង ដោយការជូនជាពត៌មានតាមទូរស័ព្ទឬសរសេរជាលាយល័ក្ខអក្សរផ្តល់ជូនទៅកាន់អាជ្ញាធរមូលដ្ឋាន (មេឃុំ ក្រុមប្រឹក្សាឃុំ ឬមេភូមិ) ឬអ្នកទទួលការសាងសង់ ឬក្រុមការងារមន្ទីរអភិវឌ្ឍន៍ជនបទឬក៏ក្រុមការងាររបស់ក្រសួងអភិវឌ្ឍន៍ជនបទដើម្បីដោះស្រាយ។ ចំពោះពត៌មានលម្អិតស្តីពីយន្តការបណ្តឹងតវ៉ា គឺមានបិទផ្សាយ និងរក្សាទុកនៅតាមសាលាឃុំ និងការដ្ឋានសាងសង់របស់អ្នកទទួលការ ដែលមានលេខទំនាក់ទំនងតាមគោលដៅនៃអនុគម្រោងនីមួយៗ។